អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស សម្រាប់ការធ្វើសេវាកម្មបញ្ជូនអគ្គិសនី ក្នុងព្រះរាជាណាចក្រកម្ពុជា

# SPECIAL PURPOSE TRANSMISSION LICENSE FOR PROVIDING TRANSMISSION SERVICE IN THE KINGDOM OF CAMBODIA

**ក្រុមហ៊ុន ធី ភី អិល ស៊ី ហូលឌីង**

**TPLC HOLDINGS LTD.**

ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩

**SEPTEMBER 16, 2009**

# ផ្នែកទី១

# សេចក្តីសម្រេចផ្តល់សិទ្ធិឱ្យធ្វើសេវាកម្ម

# PART I

# DECISION TO GRANT THE RIGHT TO PROVIDE THE ELECTRIC POWER SERVICE

# ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

**អាជ្ញាធរអគ្គិសនីកម្ពុជា**

ELECTRICITY AUTHORITY OF CAMBODIA

លេខ : ០៩-អអក

# ឯកសារអាជ្ញាប័ណ្ណលេខ ២៥២ ឯអ
## LICENSE DOCUMENT No. 252 LD

# អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស សម្រាប់ក្រុមហ៊ុន ធី ភី អិល ស៊ី ហូលឌីង
## SPECIAL PURPOSE TRANSMISSION LICENSE FOR TPLC HOLDINGS LTD

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧, ២៩ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- In exercise of the powers conferred by Article 7, 29 and 35 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated February 02, 2001.

-យោងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខ ២៥០ ឧរថ.អថ.ប្រក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨

- In accordance with PRAKAS of Ministry of Industry, Mines and Energy Nº 250 dated March 20, 2008.

-យោងតាមកិច្ចព្រមព្រៀងលក់-ទិញអគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជា និងក្រុមហ៊ុន ធី ភី អិល ស៊ី ហូលឌីង ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៩

- In accordance with Power Purchase Agreement signed between Electricité du Cambodge and TPLC Holdings Ltd dated January 02, 2009.

-យោងតាមពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន ធី ភី អិល ស៊ី ហូលឌីង ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៨

- In accordance with the application for License of TPLC Holdings Ltd, dated September 02, 2008.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកស្នើសុំអាជ្ញាប័ណ្ណ ស្ថាប័នពាក់ព័ន្ធ និងសាធារណជន ចាប់ពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

- In accordance with the consultations with the applicant, concerned parties and public, made from August 07, 2009 to September 15, 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ១៦៩ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩

- In accordance with the decision of Electricity Authority of Cambodia's Session No. 169 dated September 16, 2009.

# សម្រេច

# DECIDES

**ប្រការ១**

ផ្តល់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសជូន **ក្រុមហ៊ុន ធី ភី អិល ស៊ី ហូលឌីង** បន្ទាប់ពីនេះហៅថា **"អ្នកកាន់អាជ្ញាប័ណ្ណ"**) មានទីស្នាក់ការនៅផ្ទះលេខ ២០ ផ្លូវ ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ដែលបានចុះបញ្ជីពាណិជ្ជកម្មលេខ Co.១០២១៦/០៧P ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០០៧ នៅក្រោមបទប្បញ្ញត្តិនៃក្រមពាណិជ្ជកម្ម និងរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណដូចខាងក្រោម:

- គ្រប់គ្រង និងដំណើរការខ្សែបណ្តាញ ២២ គីឡូវ៉ុល នៅតាមបណ្តោយផ្លូវជាតិលេខ ៦អា ចាប់ពីភូមិខ្ទរ សង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ ទៅដល់តំបន់ថ្នល់កែង ឃុំសំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម, តាមបណ្តោយផ្លូវលេខ ៦១ ចាប់ពីថ្នល់កែង ទៅដល់តំបន់ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល និងចាប់ពីតំបន់ឃុំព្រែកតាមាក់ ទៅដល់តំបន់ឃុំព្រះប្រសប់ និងតំបន់ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងខ្សែបណ្តាញបំបែកពីខ្សែបណ្តាញមេ ។

- លក់អគ្គិសនីដុំឱ្យអ្នកកាន់អាជ្ញាប័ណ្ណ, អតិថិជនធុនធំ និងអតិថិជនតង់ស្យុងមធ្យមនៅតាមបណ្តោយផ្លូវជាតិលេខ ៦អា ចាប់ពីព្រំប្រទល់ចែកចាយរបស់អគ្គិសនីកម្ពុជានៅរាជធានីភ្នំពេញ ទៅដល់តំបន់ថ្នល់កែង ឃុំសំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម, តាមបណ្តោយផ្លូវលេខ ៦១ ចាប់ពីថ្នល់កែង ទៅដល់តំបន់ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល និងចាប់ពីតំបន់ឃុំព្រែកតាមាក់ ទៅដល់តំបន់ឃុំព្រះប្រសប់ និងតំបន់ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងខ្សែបណ្តាញបំបែកពីខ្សែបណ្តាញមេ ។ ដើម្បីធ្វើសេវាកម្មខាងលើ អ្នកកាន់អាជ្ញាប័ណ្ណត្រូវទិញអគ្គិសនីពីអគ្គិសនីកម្ពុជា ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងលក់-ទិញអគ្គិសនី រវាង អគ្គិសនីកម្ពុជា និង ក្រុមហ៊ុន ធីភី អិលស៊ី ហូលឌីង ដែលចុះហត្ថលេខា នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០០៩ ។

សិទ្ធិខាងលើ ត្រូវអនុលោមទៅតាមល័ក្ខខ័ណ្ឌនានារបស់អាជ្ញាប័ណ្ណ ដែលមានចែងក្នុងផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។

**Article 1**

There is hereby granted the Special Purpose Transmission License to **TPLC Holdings Ltd** (herein after referred to as **"Licensee"**) located at #20, St. 217, Sangkat Veal Vong, Khan Prampi Makara, Phnom Penh, registered in the Kingdom of Cambodia under No. 10216/07P dated June 25, 2007 pursuant to the Commercial and Civil Law for giving the right to licensee as follow:

- Own and operate 22 kV line along the National Road No. 6A from Phum Khtor, Sangkat Prek Tasek, Khan Russey Keo to Thnal Keng area, Khum Sambo, Batheay District, Kampong Cham Province, along the road no. 61 from Thnal Keng to Khum Koh Chin, Ponnhea Leu District, Kandal Province and from Khum Prek Tamak to Khum Preah Brasob and Khum Puk Reussry, Khsach Kandal District, Kandal Province and the branch lines.

- Sell electricity in bulk to other licensees, big and MV consumers along the National Road No. 6A from authorized distribution area of Electricité du Cambodge (EDC) at Phnom Penh to Thnal Keng area, Khum Sambo, Batheay District, Kampong Cham Province, along the road no. 61 from Thanl Keng to Khum Koh Chin, Ponnhea Leu District, Kandal Province and from Khum Prek Tamak to Preah Brasob and Khum Puk Ressey, Khsach Kandal District, Kandal Province and from the branch lines. To provide the above services, the Licensee will purchase electricity from EDC under the Power Purchase Agreement between EDC and TPLC Holdings Ltd, signed on January 02, 2009.

The right to provide the above electric power services shall be in accordance with conditions of license specified in part 2 of this license.

| | |
|---|---|
| **ប្រការ២**<br><br>លក្ខខណ្ឌនានារបស់អាជ្ញាប័ណ្ណនេះអាចកែសម្រួល ឬ ធ្វើវិសោធនកម្មបាន អនុលោមតាមបញ្ញត្តិរបស់អាជ្ញាប័ណ្ណនេះ ឬ តាមមាត្រា ៧ និង ៤៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាប័ណ្ណដែលផ្តល់ឱ្យនេះអាចដកហូតបាន ស្របតាមលក្ខខណ្ឌដែលកំណត់ក្នុង ឧបសម្ព័ន្ធទី២ របស់អាជ្ញាប័ណ្ណ ។ | **Article 2**<br><br>The Conditions set out in Part 2 and referred above are subject to modification or amendment in accordance with their terms or with Article 7 and 44 of Electricity Law of the Kingdom of Cambodia. The license hereby granted is further subject to the terms of revocation specified in Schedule 2 of this License. |
| **ប្រការ៣**<br><br>អាជ្ញាប័ណ្ណនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងមានអណត្តិចំនួន ១៥ (ដប់ប្រាំ) ឆ្នាំ និងអាចសុំបន្តទៀតឬស្នើសុំកែសម្រួលបានលើកលែងតែត្រូវបានដកហូតដោយអនុលោមតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណនេះ ។ | **Article 3**<br><br>This license shall come into force from the date it is signed, and unless revoked earlier in accordance with the conditions of license, the term of license shall be 15 (fifteen) years and may be renewed for further periods and with such modification as required on the application of licensee. |

ភ្នំពេញ, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩

**Phnom Penh, September 16, 2009**

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

**CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA**

# ផ្នែកទី២

# លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ

**PART II**

**CONDITIONS OF LICENSE**

# តារាងមាតិកា

TABLE OF CONTENTS


| | |
|---|---|
| **១.និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ** | **1 Definitions of Terms used in the License** |
| **២.ភារកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **2 General Obligation of Licensee** |
| **ល័ក្ខខ័ណ្ឌទី១ :** កាតព្វកិច្ចគោរពច្បាប់ អនុក្រឹត្យ បទបញ្ជា និងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី | **Condition 1:** Obligation on compliance with the Laws, Sub-decrees, Orders and Transmission Agreement |
| **ល័ក្ខខ័ណ្ឌទី២ :** កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកកាន់អាជ្ញាប័ណ្ណតាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា | **Condition 2:** Obligation on provision of Financial Statement of Licensee |
| **ល័ក្ខខ័ណ្ឌទី៣ :** កាតព្វកិច្ចធ្វើរបាយការណ៍សកម្មភាពសេវាកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណតាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា | **Condition 3:** Obligation on Provision of Information to EAC |
| **ល័ក្ខខ័ណ្ឌទី៤ :** កាតព្វកិច្ចបង់កំរៃអាជ្ញាប័ណ្ណ | **Condition 4:** Obligation on Payment of License Fees |
| **៣.ល័ក្ខខ័ណ្ឌសេវាកម្ម** | **3 Service Conditions** |
| **ល័ក្ខខ័ណ្ឌទី៥ :** ល័ក្ខខ័ណ្ឌចំពោះមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនី | **Condition 5**: Condition on Transmission/ Sub-Transmission Facilities. |
| **ល័ក្ខខ័ណ្ឌទី៦ :** ល័ក្ខខ័ណ្ឌដំណើការប្រព័ន្ធបញ្ជូនអគ្គិសនី | **Condition 6:** Condition on Operation of Transmission System. |
| **ល័ក្ខខ័ណ្ឌទី៧ :** ល័ក្ខខ័ណ្ឌចំពោះការបើកចំហរសិទ្ធិប្រើប្រាស់ និងសិទ្ធិភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនអគ្គិសនី ដោយមិនរើសអើង | **Condition 7:** Condition on providing Non-discriminatory Open Access and connection to Transmission System. |
| **ល័ក្ខខ័ណ្ឌទី៨ :** ល័ក្ខខ័ណ្ឌចំពោះការលក់អគ្គិសនីដុំឱ្យអ្នកប្រើប្រាស់ | **Condition 8:** Condition on sale of Electricity to Bulk Consumers |
| **ល័ក្ខខ័ណ្ឌទី៩ :** ល័ក្ខខ័ណ្ឌគោរពតាមកូដប្រព័ន្ធបញ្ជូន និងកូដប្រព័ន្ធចែកចាយ | **Condition** 9: Condition on compliance with Grid Code and Distribution Codes |
| **ល័ក្ខខ័ណ្ឌទី១០ :** ល័ក្ខខ័ណ្ឌចំពោះការធ្វើអាជីវកម្មអគ្គិសនី | **Condition 10:** Condition on the Business |
| **ល័ក្ខខ័ណ្ឌទី១១ :** ល័ក្ខខ័ណ្ឌសម្រាប់ថ្លៃសេវាបញ្ជូន និងថ្លៃលក់អគ្គិសនីដុំ | **Condition 11:** Condition for Tariff for transmission service and Bulk Sale. |
| **ល័ក្ខខ័ណ្ឌទី១២ :** ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី | **Condition 12:**Settlement of Disputes relating to Transmission Agreement |
| **ល័ក្ខខ័ណ្ឌទី១៣ :** ល័ក្ខខ័ណ្ឌចំពោះការផ្តល់សុខុមាលភាព និងសុវត្ថិភាពចំពោះនិយោជិត | **Condition 13:** Health and Safety of Employees |
| **ល័ក្ខខ័ណ្ឌទី១៤ :** ការទំនាក់ទំនង | **Condition 14:** Communication |
| **ល័ក្ខខ័ណ្ឌទី១៣ :** ល័ក្ខខ័ណ្ឌចំពោះការលក់មធ្យោបាយបញ្ជូន/មធ្យោបាយបញ្ជូនរងអគ្គិសនីតាមការតម្រូវរបស់អាជ្ញាធរអគ្គិសនីកម្ពុជា | **Condition 15:** Sale Conditions of the Transmission/ Sub-Transmission facility in case required by EAC |
| **ឧបសម្ព័ន្ធទី១ :** ការកំណត់បញ្ជាក់មធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ | **SCHEDULE 1:** Fixed Specified Transmission/Sub Transmission Facilities of Licensee |
| **ឧបសម្ព័ន្ធទី២ :** ល័ក្ខខ័ណ្ឌសម្រាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ | **SCHEDULE 2:** Term of Revocation |
| **ឧបសម្ព័ន្ធទី៣:** ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ | **SCHEDULE 3:** Ownership of Licensee |

# លក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ

# CONDITIONS OF LICENSE

## ១_និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ

ពាក្យពេចន៍ទាំងឡាយណាដែលបានប្រើប្រាស់ក្នុងឯកសារអាជ្ញាប័ណ្ណនេះ ឬផ្នែកណាមួយរបស់ឯកសារនេះ និងនៅក្នុងឧបសម្ព័នភ្ជាប់ ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារផ្សេងទេ ត្រូវមានន័យដូចខាងក្រោម :

**"ថាមពលសកម្ម"** មានន័យថា ថាមពលដែលផលិត លំហូរ ឬផ្គត់ផ្គង់ដោយសៀគ្វីអគ្គិសនីមួយក្នុងរយៈពេលកំណត់ (ដែលជាផលគុណនៃពេល និងអានុភាពខណៈ) ដែលវាស់តាមខ្នាតវ៉ាត់ម៉ោង (Wh) និងមានខ្នាតគុណ ដូច្នេះ 1,000 Wh = 1 Kilowatt-hour (kWh) 1,000 kWh = 1 Megawatt-hour (MWh). 1,000 MWh = 1 Gigawatt-hour (GWh) 1,000 GWh = 1 Terawatt-hour (TWh)

**"សវនកម្ម"** មានន័យថាការជំរះបញ្ជីលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកកាន់អាជ្ញាប័ណ្ណដោយសវនករមួយ ក្នុងពេលធ្វើអាជីវកម្ម ។

**"អនុញ្ញាតិ"** ពាក់ព័ន្ធនឹងអាជីវកម្ម ឬសកម្មភាព មានន័យថាការអនុញ្ញាតដែលមានចែងក្នុងអាជ្ញាប័ណ្ណនេះ ស្របតាមច្បាប់អគ្គិសនី ។

**"ល័ក្ខខ័ណ្ឌ"** មានន័យថា ជាការកំណត់ល័ក្ខខ័ណ្ឌ ឬឧបសម្ព័ន្ធចែងក្នុងអាជ្ញាប័ណ្ណនេះ ។

**"ថ្លៃភ្ជាប់ប្រព័ន្ធ"** មានន័យថា បន្ទុកត្រូវបង់ថ្លៃចំណាយសម្រាប់ការអនុវត្តន៍ការងារ ការផ្តល់សំភារៈ និងការតំឡើងនៃរោងចក្រអគ្គិសនី ខ្សែបណ្តាញអគ្គិសនី និងនាឡិកាស្ទង់ផ្ទៃក្នុង ក្នុងការសាងសង់ឬការកែសម្រួលចំណុចដែលត្រូវភ្ជាប់ចូល និងភ្ជាប់ចេញនៃប្រព័ន្ធបញ្ជូនអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

**"អ្នកប្រើប្រាស់"** មានន័យថា បុគ្គលណាមួយ ឬអ្នកទទួលសិទ្ធិបន្តដែលទិញ ឬទទួលអគ្គិសនីដើម្បីប្រើប្រាស់ និងមិនមែនដើម្បីផ្តល់ ឬលក់បន្តឱ្យអ្នកដទៃទៀតឡើយ ។ "អ្នកប្រើប្រាស់ធុនធំ" គឺជាអ្នកប្រើប្រាស់ទាំងឡាយណាដែលទទួលការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបញ្ជូនអគ្គិសនី ។

## 1- Definitions of Terms used in the License

In this License document including the Schedules, unless otherwise specified or the context otherwise require:

**"Active Energy"** means the electrical energy produced, flowing in or supplied by an electric circuit during a time interval, (being integral with respect to time of the instantaneous power), measured in units of watt-hours (Wh) and standard multiples thereof, that is: 1,000 Wh = 1 Kilowatt-hour (kWh) 1,000 kWh = 1 megawatt-hour (MWh). 1,000 MWh = 1 gigawatt-hour (GWh) 1,000 GWh = 1 terawatt-hour (TWh).

**"Audit"** means the audit of the Licensee's Financial Statements by any qualified auditor for the time being providing auditing business.

**"Authorized"** in relation to any business or activity means Authorized by license granted under the Electricity Law.

**"Condition"** means a definition, condition or schedule set out in this License.

**"Connection Charges"** means charges made for carrying out of works and provision and installation of electrical plant, electric lines and meters in constructing or modifying entry and exit points on Licensee's Transmission System.

**"Consumer"** means a person or his successor that purchases or receives electricity for consumption and not for delivery or resale to other. "Bulk Consumer" is the consumer supplied from the Transmission System.

| | |
|---|---|
| **“អ្នកប្រើប្រាស់ធុនធំ”** គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់ជាទូទៅពីបន្ទប់ភ្លើង MV/LV ដាច់ដោយឡែកនៅក្នុងទីតាំងរបស់អ្នកប្រើប្រាស់តាមតង់ស្យុង ៤០០វ៉ុល ៣ហ្វា និងត្រូវការកម្លាំងលើសពី ១៥០អំពែរ រហូតដល់តិចជាង ៤០០អំពែរ ។ ក្នុងករណីខ្លះ បើអ្នកផ្គត់ផ្គង់ពិនិត្យឃើញថាអាចអនុវត្តបានសម្រាប់អ្នកប្រើប្រាស់ដែលប្រើប្រាស់អនុភាពមួយផ្នែកនៃបន្ទប់ភ្លើង ការផ្គត់ផ្គង់អាចបន្តចេញតាមខ្សែតង់ស្យុងទាបដាច់ដោយឡែកពីបន្ទប់ភ្លើងសាធារណៈ ។ នាឡិកាស្ទង់ត្រូវតម្លើងនៅលើទ្វារចរន្តនៅបន្ទប់ភ្លើងនោះ ។ | **“Big Consumers”** mean a consumer requiring power more than 150 amperes and less than 400 amperes at three phase 400 volts is categorized as Big Consumer. Big Consumers will be supplied power generally from a separate MV/LV substation on their premises. The meter will be installed indoors or close to the substation. In some cases, if found feasible by the licensee, the supply to Big Consumers can be given by partly utilizing the capacity of a public MV/LV substation through a separate LV feeder. The meter will be installed at the substation on this feeder. |
| **“អ្នកប្រើប្រាស់តង់ស្យុងមធ្យម”** គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់ពីខ្សែបណ្ដាញតង់ស្យុងមធ្យម ។ | **"MV Consumer"** means the consumer supplied at MV. |
| **“អ្នកប្រើប្រាស់ដុំ”** គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់ពីខ្សែបណ្ដាញបញ្ជូនតង់ស្យុងខ្ពស់ ។ | **"Bulk Consumer"** means the consumer supplied from the Transmission System. |
| **“មជ្ឈមណ្ឌលបញ្ជា”** មានន័យថា ជាទីកន្លែងដែលប្រើប្រាស់សម្រាប់គោលបំណងត្រួតពិនិត្យនិងដំណើការប្រព័ន្ធបញ្ជូនអគ្គិសនីឬផ្នែកមួយនៃប្រព័ន្ធបញ្ជូន និងប្រព័ន្ធរបស់អ្នកប្រើប្រាស់ដែលភ្ជាប់ជាមួយ នៅក្នុងប្រទេសកម្ពុជា ។ | **“Control Center”** means the location used for the purpose of control and operation of the Transmission System or a part of it and the connected user’s system in Cambodia. |
| **“កូដប្រព័ន្ធចែកចាយ”** ជាក្បួនច្បាប់ដែលគ្របដណ្ដប់លើទិដ្ឋភាពបច្ចេកទេសធំៗទាំងអស់ដែលពាក់ព័ន្ធជាមួយការតភ្ជាប់ ការដំណើរការ និងការប្រើប្រាស់ប្រព័ន្ធចែកចាយរបស់បុគ្គលណាមួយដែលបានទទួលការអនុញ្ញាតឱ្យផ្គត់ផ្គង់សេវាកម្មចែកចាយ ។ | **“Distribution Code”** means the Distribution Code covering all material technical aspects relating to connections to and the operation and use of the Distribution System of a person Authorized to provide distribution service. |
| **“ប្រព័ន្ធចែកចាយ”** មានន័យថា ខ្សែបណ្ដាញអគ្គិសនីទាំងអស់របស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងតំបន់ចែកចាយដែលបានអនុញ្ញាត និងខ្សែបណ្ដាញអគ្គិសនីណាមួយផ្សេងទៀតដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចបញ្ជាក់ថា ជាផ្នែកនៃប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណព្រមទាំងនាឡិកាស្ទង់ និងបរិក្ខាអគ្គិសនីណាមួយរបស់អ្នកកាន់អាជ្ញាប័ណ្ណដែលបានប្រើប្រាស់សម្រាប់ចែកចាយអគ្គិសនីដោយអ្នកកាន់អាជ្ញាប័ណ្ណ ដោយឡែក ចំពោះអ្នកចែកចាយដទៃណា | **“Distribution System”** means all electric network of distribution licensee within the distribution licensee’s authorized distribution area and any other electric network which EAC may specify as forming part of the distribution licensee’s Distribution System, and includes any electrical plant and meters of the distribution licensee which are used in connection with the distribution of electricity by the distribution licensee. |

| | | | |
|---|---|---|---|
| | មួយផ្សេងទៀត វាមានអត្ថន័យដូចគ្នា ដូចមានចែងក្នុងអាជ្ញាប័ណ្ណដែលបានកាន់ដោយអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនោះ ។ | | |
| **"អាជ្ញាធរអគ្គិសនីកម្ពុជា"** | មានន័យថា អាជ្ញាធរដែលបានបង្កើតឡើងដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ។ | **"EAC"** | means the Electricity Authority of Cambodia established by the Electricity Law promulgated by Royal Decree No. NS/RKM/0201/03 dated 2 February 2001. |
| **"អគ្គិសនីកម្ពុជា"** | មានន័យថា ក្រុមហ៊ុនអគ្គិសនីកម្ពុជាដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខនស/រកត/០៣៩៦/១០ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៦ ។ | **"EDC"** | means the Electricité du Cambodge, established by Royal Decree No. ChS/RKT/0396/10 dated March 09, 1996. |
| **"ច្បាប់អគ្គិសនី"** | មានន័យថា ច្បាប់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២០១/០៣ ។ | **"Electricity Law"** | means the Electricity Law of the Kingdom of Cambodia, promulgated by the Royal Decree No. NS/RKM/ 0201/03 dated 2 February 2001. |
| **"កូដប្រព័ន្ធបញ្ជូន"** | ជាក្បួនច្បាប់ដែលគ្របដណ្តប់លើសកម្មភាពទាំងអស់ដែលពាក់ព័ន្ធជាមួយការតភ្ជាប់ ការដំណើរការ និងការប្រើប្រាស់ប្រព័ន្ធបញ្ជូន រួមមានការដំណើការខ្សែបណ្តាញ និងរោងចក្រផលិតអគ្គិសនី ដែលភ្ជាប់នឹងប្រព័ន្ធបញ្ជូននោះ ។ | **"Grid Code"** | means the code covering all activities relating to the connections, operation and use of Transmission System, including the operation of electric lines and electrical plant connected to the Transmission System. |
| **"ឯកសារអាជ្ញាប័ណ្ណ"** | មានន័យថា ឯកសារនេះដែលមានពីផ្នែកទី១ ដល់ផ្នែកទី២ និងឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៣ ។ | **"License"** | means this document comprising Parts 1, Part 2 and Schedules 1 to 3 of this License. |
| **"អ្នកកាន់អាជ្ញាប័ណ្ណ"** | មានន័យថា**ក្រុមហ៊ុន ធី ភី អិល ស៊ី ហូលឌីង** | **"Licensee"** | means **TPLC Holdings Ltd** |
| **"បរិក្ខានាឡិកាស្ទង់"** | រួមមាននាឡិកាស្ទង់ និងបរិក្ខាពាក់ព័ន្ធ ដទៃទៀតដែលមានឥទ្ធិពលផ្ទាល់លើការដំណើរការនាឡិកាស្ទង់នោះ ។ | **"Meter"** | includes any meter and associated equipment which materially affects the operation of that meter. |
| **"ការជូនដំណឹង"** | មានន័យថា (ប្រសិនបើពុំមានការបញ្ជាក់ផ្សេងទៀត)ការជូនដំណឹងជាលាយលក្ខណ៍ អក្សរ ឬដោយមធ្យោបាយសមស្របណាមួយផ្សេងទៀត ។ | **"Notice"** | means (unless otherwise specified) notice given in writing or by any other reasonable means. |
| **"កិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី"** | មានន័យថាកិច្ចព្រមព្រៀងរវាងអ្នកកាន់អាជ្ញាប័ណ្ណណាមួយ និងអ្នកប្រើប្រាស់ដែលប្រើប្រាស់ប្រព័ន្ធបញ្ជូនរបស់ខ្លួនសម្រាប់ផ្តល់សេវា និងធ្វើឱ្យមានសេវាកម្មបញ្ជូន ហើយបានទទួលការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ | **"Transmission Agreement"** | means the agreement between the Licensee and the user of its Transmission System for providing and availing the transmission service and approved by EAC. |
| **"អាជីវកម្មបញ្ជូនអគ្គិសនី"** | មានន័យថា ជាអាជីវកម្មដោយមានការអនុញ្ញាតរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងការធ្វើផែនការ ការ | **"Transmission Business"** | means the authorized business of the Licensee in the planning, development, |

| | |
|---|---|
| អភិវឌ្ឍន៍ ការសាងសង់ ការដំណើការ និងការថែទាំប្រព័ន្ធបញ្ជូនរបស់អ្នកកាន់អាជ្ញាប័ណ្ណដោយរួមបញ្ចូលទាំងការផ្គត់ផ្គង់ដែលភ្ជាប់នឹងប្រព័ន្ធបញ្ជូននេះផង ។ | construction, operation and maintenance of its Transmission System, including any business in providing connections to its Transmission System. |
| **"មធ្យោបាយបញ្ជូនអគ្គិសនី"** មានន័យថា ជាមធ្យោបាយសំខាន់ៗរួមមានខ្សែបណ្តាញអគ្គិសនីតង់ស្យុងខ្ពស់ជាមាស់កម្មសិទ្ធិ ឬដំណើការដោយអ្នកកាន់អាជ្ញាប័ណ្ណច្រើន និងប្រើប្រាស់សម្រាប់បញ្ជូនអគ្គិសនីពីរោងចក្រអគ្គិសនីមួយ ទៅអនុស្ថានីយមួយ ឬទៅរោងចក្រអគ្គិសនីមួយទៀត ឬរវាងអនុស្ថានីយ ឬទៅ ឬមកពីការតភ្ជាប់ពីខាងក្រៅណាមួយ ហើយរួមមានអនុស្ថានីយតង់ស្យុងខ្ពស់/តង់ស្យុងមធ្យម រោងចក្រណាមួយ និងបរិក្ខាផ្សេងៗ និងប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធការពារ ប្រព័ន្ធនាឡិកាស្ទង់ និងមធ្យោបាយគមនាគមន៍ដែលជាកម្មសិទ្ធិ និងដំណើការដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ក្នុងការភ្ជាប់ជាមួយខ្សែបណ្តាញបញ្ជូនល្អត្រឹមត្រូវមួយ រហូតដល់ចំណុចតភ្ជាប់នៃប្រព័ន្ធនេះ ជាមួយនិងប្រព័ន្ធរងបញ្ជូន ឬប្រព័ន្ធចែកចាយ ។ | **"Transmission Facility"** means the facility consisting mainly of high voltage electric lines owned or operated by the Licensees and used for the transmission of electricity from one generating station to a substation or to another generating station or between substations or to or from any external interconnection and includes the HV/MV substation, any plant and apparatus and associated control, protection, metering and communication facilities owned and operated by transmission licensees in connection with proper transmission of electricity up to the interconnection with the Sub-transmission system or distribution System. |
| **"អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន"** មានន័យថា ជាបុគ្គល/នីតិបុគ្គលដែលកាន់អាជ្ញាប័ណ្ណបញ្ជូន ។ | **"Transmission Licensee"** means a person/a company who holds a Transmission License. |
| **"ប្រព័ន្ធបញ្ជូន"** មានន័យថា ជាប្រព័ន្ធដែលរួមមានមធ្យោបាយបញ្ជូនអគ្គិសនី និងមធ្យោបាយរងបញ្ជូនអគ្គិសនី ។ | **"Transmission System"** means the system consisting of the Transmission Facilities and Sub-Transmission facilities. |
| **"មធ្យោបាយរងបញ្ជូនអគ្គិសនី"** មានន័យថាជាប្រព័ន្ធដែលរួមមានផ្នែកសំខាន់ៗនៃខ្សែបណ្តាញតង់ស្យុងមធ្យម ប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធការពារ និងប្រព័ន្ធនាឡិកាស្ទង់ ដែលជាកម្មសិទ្ធ និងដំណើការដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ហើយប្រើប្រាស់សម្រាប់ផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណដទៃទៀតឬអ្នកប្រើប្រាស់ធុនធំ ។ | **"Sub-Transmission Facility"** means the system consisting mainly of medium voltage electric lines and associated control, protection and metering facility owned or operated by transmission licensees and used for supply of electricity to other licensees or Bulk Consumers. |
| **"កិច្ចព្រមព្រៀងផ្គត់ផ្គង់"** មានន័យថាកិច្ចព្រមព្រៀងរវាងអ្នកកាន់អាជ្ញាប័ណ្ណ និងអ្នកប្រើប្រាស់ធុនធំ ឬអ្នកកាន់អាជ្ញាប័ណ្ណមួយផ្សេងទៀត សម្រាប់លក់អគ្គិសនីដុំ ។ | **"Supply Agreement"** means the agreement between the Licensee and the Bulk Consumer or another licensee for sale of electricity in bulk. |
| **២ ភាតព្វកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **2.General Obligation of Licensee** |
| **លក្ខខណ្ឌទី១: ភាតព្វកិច្ចគោរពច្បាប់ អនុក្រឹត្យ បទបញ្ជា និងកិច្ចព្រមព្រៀងបញ្ជូន** | **Condition 1: Obligation on compliance with the Laws, Sub-Decrees, Orders and Transmission agreement** |

| | |
|---|---|
| ១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា លក្ខខ័ណ្ឌអាជ្ញាប័ណ្ណ និងច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធជាមួយច្បាប់ ។ | 1- The Licensee shall comply with the Electricity Law, conditions of the License and all other applicable laws and sub-decrees, regulations issued under these laws. |
| ២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមបទបញ្ជារ សេចក្តីជូនដំណឹង និង សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីស្របតាមច្បាប់អគ្គិសនី និង លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះ ។ | 2- The Licensee shall comply with any order, direction and determination made by EAC pursuant to the Electricity Law and this License. |
| ៣- អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការប្រព័ន្ធបញ្ជូន និងគ្រប់គ្រងអាជីវកម្មបញ្ជូនរបស់ខ្លួនឱ្យមានប្រសិទ្ធភាពស្របតាមលក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះ និងស្របតាមកិច្ចព្រមព្រៀងបញ្ជូនណាមួយដែលអ្នកកាន់អាជ្ញាប័ណ្ណបានបញ្ចូល និងមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ | 3- The Licensee shall operate the Transmission System and manage its Transmission Business in an efficient manner in accordance with the requirement of this License and any Transmission Agreement(s) that the Licensee has entered into and approved by EAC. |
| ៤- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមកាតព្វកិច្ចបរិស្ថានដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និងអនុក្រឹត្យនានាពាក់ព័ន្ធនឹងការការពារបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។ | 4- The Licensee is subjected to the environmental obligations as specified in the Law on Environmental Protection promulgated by the Royal Decree NS/RKM/1296/36, dated 24/12/1996 and other Sub-Decrees on Environmental Protection in the Kingdom of Cambodia. |
| **លក្ខខ័ណ្ឌទី២: ភារកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **Condition 2: Obligation on provision of Financial Statement of Licensee** |
| ១- ឆ្នាំការិយបរិច្ឆេទនៃអ្នកកាន់អាជ្ញាប័ណ្ណ ត្រូវចាប់គិតពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។ | 1- The financial year of the Licensee shall be reckoned every year from 1st January to the following 31st December. |
| ២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវកត់ត្រារាល់ចំណូល-ចំណាយរបស់ខ្លួន និង ផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវច្បាប់ចំលង របាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចមិនលើសពី ៦ខែ ក្រោយពីបញ្ចប់ឆ្នាំការិយបរិច្ឆេទដែលរបាយការណ៍នោះពាក់ព័ន្ធ ។ | 2- The Licensee shall keep accounting records and deliver to EAC the audited financial statements not later than six months after the end of the financial year to which they relate. |
| **លក្ខខ័ណ្ឌទី៣: ភារកិច្ចធ្វើរបាយការណ៍សកម្មភាពសេវាកម្មរបស់ខ្លួន តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា** | **Condition 3: Obligation on Provision of Information to EAC** |
| ១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវបណ្តាព័ត៌មានទាំងឡាយ និងរបាយការណ៍ដែលអាជ្ញាធរទាមទារជាបន្តបន្ទាប់ តាមបែបបទ និងទម្រង់កំណត់ដោយអាជ្ញាធរ ដើម្បីអាចឱ្យអាជ្ញាធរផ្ទៀងផ្ទាត់មើលការអនុវត្តន៍របស់អ្នកកាន់អាជ្ញាប័ណ្ណ តាមលក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ និង តាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗទៀត ។ | 1- The Licensee shall furnish, in the manner and form and at the time determined by EAC, such information and such reports as EAC may require for monitoring the Licensee's compliance with the conditions of this License, the provisions of the Electricity Law and any other legislative or regulatory requirements. |
| ២- ដោយមិនគិតពីភាពទូទៅនៃវាក្យខ័ណ្ឌទី១ អាជ្ញាធរអគ្គិសនីកម្ពុជា អាចទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់នូវព័ត៌មានណាមួយ ឱ្យមានលក្ខណៈលំអិតខ្លាំងជាង ឬខុសពីការផ្តល់ព័ត៌មានធម្មតាដល់អាជ្ញាធរអគ្គិសនីកម្ពុជា ។ | 2- Without prejudice to the generality of paragraph 1, EAC may require the Licensee to furnish information which is more extensive than or differs from that required to be prepared and supplied to EAC. |

**លក្ខខណ្ឌទី៤ : ភារកិច្ចបង់កម្រៃអាជ្ញាប័ណ្ណ**

១- ចាប់ពីថ្ងៃចូលជាធរមានរហូតដល់ថ្ងៃបញ្ចប់អាណត្តិនៃអាជ្ញាប័ណ្ណនេះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវ**កំរៃអាជ្ញាប័ណ្ណប្រចាំខែ** តាមអាត្រាកំរៃអាជ្ញាប័ណ្ណ និងរូបមន្តគណនាកំរៃអាជ្ញាប័ណ្ណ ដែលត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជាសម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ដោយអនុលោមតាមមាត្រា២៧ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣នៃអនុក្រឹត្យស្តីពីការកំណត់កំរិតអតិបរមានៃកំរៃអាជ្ញាប័ណ្ណ សម្រាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- វិក្កយបត្រនៃកំរៃអាជ្ញាប័ណ្ណប្រចាំខែ ត្រូវចាត់ទុកថាជំពាក់ និងត្រូវបង់ក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអ្នកកាន់អាជ្ញាប័ណ្ណបានទទួលវិក្កយបត្រ ។

## ៣_លក្ខខណ្ឌសេវាកម្ម

**លក្ខខណ្ឌទី៥: លក្ខខណ្ឌចំពោះមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនី**

១- អាជ្ញាប័ណ្ណនេះផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិធ្វើសេវាកម្មបញ្ជូនអគ្គិសនីដោយដំណើរការលើប្រព័ន្ធបញ្ជូនអគ្គិសនី / ប្រព័ន្ធបញ្ជូនរងអគ្គិសនីដែលមានកំណត់ច្បាស់លាស់ក្នុងឧបសម្ព័ន្ធ១នៃអាជ្ញាប័ណ្ណនេះ ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវធានាថា ប្រព័ន្ធបញ្ជូនរបស់ខ្លួនអនុវត្តន៍តាមស្តង់ដាបច្ចេកទេស ចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

៣- អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ប្រព័ន្ធនាឡិកាស្ទង់សមស្រប សម្រាប់វាស់បរិមាណថាមពលនាំចូល និងនាំចេញតាមមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

**លក្ខខណ្ឌទី៦ : លក្ខខណ្ឌដំណើរការប្រព័ន្ធបញ្ជូនអគ្គិសនី**

១- នៅពេលមជ្ឈមណ្ឌលបញ្ជាប្រកាសឱ្យប្រើប្រាស់សេចក្តីណែនាំ អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការមធ្យោបាយបញ្ជូនរងអគ្គិសនីរបស់ខ្លួនតាមការណែនាំនោះ, ក្នុងករណីពុំទាន់មាន អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមគោលការណ៍អនុវត្តរបស់សហគ្រាសអគ្គិសនីដែលមានបទពិសោធន៍ល្អ ។

**លក្ខខណ្ឌទី៧ : លក្ខខណ្ឌចំពោះការបើកចំហសិទ្ធិប្រើប្រាស់និងការតភ្ជាប់ជាមួយប្រព័ន្ធបញ្ជូន**

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបើកចំហដោយគ្មានការរើសអើងឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀត និងអតិថិជនធុនធំ ប្រើប្រាស់ប្រព័ន្ធបញ្ជូនរបស់ខ្លួន ក្នុងករណីដែលប្រព័ន្ធបញ្ជូននោះ មានសមត្ថភាពអាចទទួលយក

**Condition 4: Obligation on Payment of License Fees**

1- From the effective date until the end of the term of the License, the Licensee shall pay to EAC a monthly license fee, which is calculated according to the rate(s) of license fee(s) and the formula determined by EAC for each financial year pursuant to Article 27 of Electricity Law and Article 3 of Sub Decree defining the maximum license fee for electric power services in the Kingdom of Cambodia.

2- Each invoice of monthly license fee shall be due and payable within 14 days after the day on which the Licensee receives it.

## 3-Service Conditions

**Condition 5: Condition on Transmission/ Sub-Transmission Facilities**

1- This License grants the right to the Licensee to provide transmission service by operating the specific Transmission/ Sub-Transmission Facilities specified in Schedule 1.

2- The Licensee shall ensure that its Transmission System meet the Technical Standards issued by the Ministry of Industry, Mines and Energy.

3- The Licensee shall provide suitable Meters to measure electrical quantities imported and exported by the Transmission/Sub-Transmission Facility of the Licensee.

**Condition 6: Condition on Operation of Transmission System**

1- The Licensee shall operate its Sub-transmission Facility as per instructions of the Control Center, when such instructions are issued, otherwise the Licensee shall follow best utility practices.

**Condition 7:Condition on providing Non-discriminatory Open Access and connection to Transmission System**

1- The Licensee shall provide non discriminatory open access to its Transmission System for use of other licensees and the Bulk Consumers subject to availability of transmission capacity and

| | |
|---|---|
| បន្ទុកនោះ និងអ្នកប្រើប្រាស់យល់ព្រមបង់កម្រៃប្រើប្រាស់ និងកម្រៃផ្សេងទៀត តាមបទបញ្ញត្តិដែលយល់ព្រមដោយអាជ្ញាធរអគ្គិសនី ។ | the user agreeing to pay all applicable charges and further subject to the regulations approved by EAC. |
| ២- ការស្នើសុំរបស់បុគ្គលណាមួយដែលមានបំណងប្រើប្រព័ន្ធបញ្ជូននេះ ឬកែសម្រួលការភ្ជាប់ដែលមានស្រាប់ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើកិច្ចសន្យាជាមួយបុគ្គលនេះ សម្រាប់ការភ្ជាប់ជាមួយប្រព័ន្ធបញ្ជូន ឬកែសម្រួលការភ្ជាប់ដែលមានស្រាប់នេះ ។ អ្នកកាន់អាជ្ញាប័ណ្ណ និងអ្នកមានបំណងប្រើប្រព័ន្ធនេះ អាចព្រមព្រៀងគ្នាលើចំណាយទាំងអស់/ចំណាយមួយផ្នែក និងរួមបញ្ចូលថ្លៃតុល្យការសម្រាប់ការកំណត់កម្រៃបញ្ជូននេះ ។ | 2- On application made for grant of a connection by any person intending to use the Transmission System or modification of an existing connection, the Licensee shall offer to enter into an agreement with such person for connection to the Transmission System or for modification of an existing connection. The Licensee and intended user may mutually agree for either payment of full/part connection charges and include the balance amount for determination of the transmission tariff. |
| ៣- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់អាណត្តិកិច្ចព្រមព្រៀងឱ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន ដល់អ្នកដែលចង់ប្រើប្រាស់ប្រព័ន្ធនេះ ។ អ្នកកាន់អាជ្ញាប័ណ្ណ មិនត្រូវកិច្ចចុះកិច្ចសន្យាណាមួយទេ ប្រសិនបើ : | 3- The Licensee shall offer terms for agreements as soon as practicable to the intended users of the Transmission System. The Licensee shall not be obliged to offer to enter into any agreement if : |
| ក- សមត្ថភាពបញ្ជូនមិនមានសល់នៅក្នុងប្រព័ន្ធ ដោយហេតុថាអាចមានវិវាទណាមួយកើតឡើងចំពោះសមត្ថភាពបញ្ជូនរបស់ប្រព័ន្ធ អាជ្ញាធរអគ្គិសនីកម្ពុជា នឹងធ្វើការសម្រេចចុងក្រោយ ដើម្បីបញ្ចប់វិវាទនេះ ។ | (a) adequate transmission capacity is not available in the Transmission System, provided that in case of any dispute pertaining to the existence or absence of such available capacity, the decision of EAC shall be final; |
| ខ- មានការរំលោភលើច្បាប់អគ្គិសនី កូដបញ្ជូន កូដចែកចាយ វិធាន ឬ បទបញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាព ឬស្តង់ដារអនុវត្តចំពោះអាជីវកម្ម បញ្ជូនអគ្គិសនី ។ | (b) it is likely to result in breach of Electricity Law, Grid Code, Distribution Code, any Rules or Regulations relating to safety or Standards applicable to the Transmission Business; |
| គ- បុគ្គលដែលកំពុងស្នើសុំមិនអនុវត្តតាមកូដប្រព័ន្ធបញ្ជូន និងកូដប្រព័ន្ធចែកចាយ ដែលបុគ្គលនោះអាចអនុវត្ត ។ | (c) the person making the application does not undertake to comply with the Grid Code and Distribution Code to the extent that they are applicable to that Person; or |
| ឃ-បុគ្គលដែលកំពុងស្នើសុំមិនបានបង់ថ្លៃផ្សេងៗ រួមមាន ថ្លៃកែតម្រូវការបាត់បង់ថាមពលអគ្គិសនីក្នុងប្រព័ន្ធបញ្ជូន ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ | (d) the person making the application does not undertake to pay all applicable charges, including adjustment for losses of electricity in the Transmission Systems determined by EAC. |
| ៤- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំ និងដាក់ជូនអាជ្ញាធរនូវរបាយការណ៍ប្រចាំឆ្នាំ ដែលបង្ហាញពីការព្យាករណ៍សមត្ថភាពរបស់សៀគ្វី អំពីលំហូរថាមពល និងបន្ទុកនៅលើផ្នែកផ្សេងៗនៃប្រព័ន្ធបញ្ជូន ស្របតាមលក្ខណៈផែនការស្តង់ដា រួមជាមួយ : | 4- The Licensee shall prepare and submit to EAC on an annual basis, a statement showing forecasts of circuit capacity, power flows and loading on different elements of the Transmission System under standard planning criteria in respect of each of the seven succeeding year, together with: |
| ក- ព័ត៌មានបន្ថែមដែលចាំបាច់និងសមហេតុផល ដើម្បីអាចឱ្យបុគ្គលណាមួយដែលចង់ប្រើប្រព័ន្ធនេះ អាចវិភាគ និងវាយតម្លៃលើលទ្ធភាពសម្រាប់តភ្ជាប់ និងប្រើប្រាស់ប្រព័ន្ធនេះ ។ | (a) such further information as shall be reasonably necessary to enable any person seeking use of System to identify and evaluate the opportunities available when connecting to and making use of such system; and |
| ខ- ព័ត៌មានផ្សេងទៀតត្រូវបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាជាបន្តបន្ទាប់សម្រាប់គោលបំណងនៃល័ក្ខខ័ណ្ឌនេះ ។ | (b) such other information as shall be specified in directions issued by EAC from time to time for the purpose of this condition. |
| ៥- អ្នកកាន់អាជ្ញាប័ណ្ណអាចយកសោហ៊ុយចំណាយលើការផ្តល់ ឬផ្ញើ | 5- The Licensee may make a charge for any statement given or sent |

ពិតមានឱ្យបុគ្គលដែលមានបំណងប្រើប្រាស់ប្រព័ន្ធបញ្ជូននេះតាមចំនួនមួយឆ្លុះបញ្ចាំងថ្លៃសមស្របសម្រាប់ចំណាយលើការផ្តល់ព័ត៌មាននេះ ។

**លក្ខខណ្ឌទី៨: លក្ខខណ្ឌស្តីពីការលក់អគ្គិសនីដុំឱ្យអតិថិជន**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវសុំការឯកភាពពីអាជ្ញាធរអគ្គិសនីជាមុន មុនពេលដំណើរការកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្សេង អតិថិជនតង់ស្យុងមធ្យម និងអតិថិជនធុនធំ ។

២- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវកែខ្លឹមសារនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់អគ្គិសនី ដោយគ្មានការឯកភាពពីអាជ្ញាធរអគ្គិសនី ជាមុនឡើយ ។

**លក្ខខណ្ឌទី៩: លក្ខខណ្ឌគោរពតាមកូដប្រព័ន្ធបញ្ជូន កូដប្រព័ន្ធចែកចាយ និងស្តង់ដាប្រតិបត្តិ**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមខ្លឹមសារដែលមានចែងនៅក្នុងកូដប្រព័ន្ធបញ្ជូន ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងកូដប្រព័ន្ធចែកចាយរបស់កាន់អាជ្ញាប័ណ្ណចែកចាយដែលភ្ជាប់នឹងប្រព័ន្ធបញ្ជូននេះ និងមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា នេះជាការអនុវត្តតាមគោលការណ៍អាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

៣- ក្នុងករណីជាក់ស្តែង ក្រោយពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីណែនាំដើម្បីបន្ធូរកាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដែលត្រូវគោរពតាមកូដប្រព័ន្ធចែកចាយ ឬខ្លឹមសារដែលកំណត់ក្នុងសេចក្តីណែនាំ ។

៤- អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការប្រព័ន្ធបញ្ជូនអគ្គិសនីស្របតាមស្តង់ដាប្រតិបត្តិដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

**លក្ខខណ្ឌទី១០: លក្ខខណ្ឌអាជីវកម្ម**

១- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវទទួលយកមធ្យោបាយបញ្ជូនអគ្គិសនី/ មធ្យោបាយបញ្ជូនរងអគ្គិសនីណាមួយបន្ថែមទៀត ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

២- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវមានភាគហ៊ុន ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយដែលអាជ្ញាប័ណ្ណមិនអនុញ្ញាត មានដូចជា អាជីវកម្មផលិតកម្ម អាជីវកម្មបញ្ជូន អាជីវកម្មចែកចាយ ឬផ្គត់ផ្គង់ថាមពល ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណ មិនត្រូវប្រើប្រាស់អចលនទ្រព្យនៃអាជីវកម្មរបស់អាជ្ញាប័ណ្ណនេះសម្រាប់គោលបំណងអ្វីក្រៅពីអាជីវកម្ម ដែលបានអនុញ្ញាតដូចកំណត់ក្នុងឯកសារនេះ ដោយពុំមានការអនុម័តជាមុនពី

to persons seeking use of the Transmission System, of an amount reflecting the Licensee's reasonable costs of providing such a statement.

**Condition 8: Conditions on sale of Electricity to Bulk Consumers**

1- The Licensee shall obtain prior approval of EAC before execution of the Supply Agreement for sale of electricity to other licensees, MV Consumers and Big Consumers.

2- The Licensee shall not revise the context of the Supply Agreement without prior approval of EAC.

**Condition 9: Conditions on compliance with Grid Code, Distribution Codes and operating Standard**

1- The Licensee shall comply with the provisions of the Grid Code approved by EAC.

2- The Licensee shall comply with the provisions of the Distribution Code of distribution licensees connected to its system and approved by EAC insofar as applicable to the Authorized business of the Licensee.

3- In specific case, EAC may (following consultation with concerned distribution licensee) issue directions relieving the Licensee of its obligation to comply with the Distribution Code or certain provisions of it as specified in the directions.

4- The Licensee shall operate the Transmission System in accordance with the Operating Standards approved by EAC.

**Condition 10: Conditions on the Business**

1- The licensee shall not acquire any additional transmission/ sub-transmission facility without the prior approval in writing of EAC.

2- The Licensee shall not acquire or associate itself with any additional business, which is not permitted by the License, including the business of generation, transmission, distribution or supply of energy, without the prior approval in writing of EAC.

3- The Licensee shall not use the assets of this License's business for the purpose other than the purpose specified in Article 1, Part 1of this License without prior written approval of EAC.

អាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៤- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវចុះកិច្ចព្រមព្រៀងជាមួយភាគីទី៣ ដើម្បីទិញអគ្គិសនីដោយគ្មានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៥- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវកែសម្រួលខ្លឹមសារនៃកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនីដែលមានចែងក្នុងអាជ្ញាប័ណ្ណ ឬចុះកិច្ចព្រមព្រៀងថ្មីណាមួយ ដោយពុំមានការអនុម័តជាមុន ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៦- នៅគ្រប់ពេល អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវប្រគល់អាជ្ញាប័ណ្ណ ឬផ្ទេរការកាន់កាប់របស់ខ្លួន ឬផ្នែកណាមួយរបស់វា ដោយលក់ បញ្ចាំ ជួល ប្តូរ ឬផ្សេងពីនេះ លើកលែងតែមានកំណត់ក្នុងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី និង/ឬអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

៧- អ្នកមានភាគហ៊ុនជាមួយអ្នកកាន់អាជ្ញាប័ណ្ណនេះ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ៣ មិនត្រូវមានភាគហ៊ុន ឬមានអត្ថប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀត ដោយគ្មានការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៨- កិច្ចព្រមព្រៀងណាមួយពាក់ព័ន្ធជាមួយកិច្ចការ ដែលបានអធិប្បាយក្នុងវាក្យខ័ណ្ឌទី១, ២, ៣, ៤, ៥, ៦ និង ៧ ខាងលើ បើពុំមានការឯកភាព ជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាទេ ត្រូវចាត់ទុកថាជាមោឃៈ និងត្រូវទុកជាការរំលោភលើល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ។

**លក្ខខ័ណ្ឌទី១១ : លក្ខខ័ណ្ឌចំពោះបញ្ជីថ្លៃលក់សម្រាប់សេវាកម្មបញ្ជូនអគ្គិសនី និងការលក់ដុំ**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់សេវាកម្មបញ្ជូន ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ជាបន្តបន្ទាប់ ។

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវអនុវត្តបញ្ជីថ្លៃលក់សម្រាប់ការលក់អគ្គិសនីឱ្យអតិថិជនធុនធំ ឬអ្នកកាន់អាជ្ញាប័ណ្ណផ្សេង ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ជាបន្តបន្ទាប់ ។

**លក្ខខ័ណ្ឌទី១២ : ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី**

១- វិវាទ ឬជម្លោះណាមួយរវាងអ្នកកាន់អាជ្ញាប័ណ្ណ និងភាគីចុះកិច្ចព្រមព្រៀងបញ្ជូន ពាក់ព័ន្ធនឹងព្រមព្រៀងបញ្ជូននេះ ត្រូវដោះស្រាយស្របតាមខ្លឹមសារដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។

**លក្ខខ័ណ្ឌទី១៣ : សុខុមាលភាព និងសុវត្ថិភាពនៃនិយោជិត**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវពិភាក្សាជាមួយនិយោជិតរបស់ខ្លួន ដើម្បីរកហេតុផល ធ្វើយ៉ាងណាឱ្យនិយោជិតបម្រើការនោះមានសុខុមាលភាព និងសុវត្ថិភាព ។

**លក្ខខ័ណ្ឌទី១៤ : ការទំនាក់ទំនង**

4- The Licensee shall not enter into any arrangements with third party for purchase of electricity without prior approval of EAC.

5- The Licensee shall not revise the context of the Transmission Agreement registered in this License or enter into any new Transmission Agreement without prior approval of EAC.

6- The Licensee shall not, at any time, assign this License or transfer its undertaking, or any part thereof, by sale, mortgage, lease, exchange or otherwise, unless specified in the Transmission Agreement and/or approved by EAC.

7- The shareholders of the Licensee, defined in Schedule 3, shall not own the shares in or have any other direct financial interest in any other licensee without prior approval of EAC.

8- Any agreement relating to any transaction of the nature described above at paragraph 1, 2, 3, 4, 5, 6 and 7, unless made with the prior written consent of EAC, shall be void and would constitute violation of Conditions of this License.

## Condition 11: Condition on Tariff for transmission service and Bulk Sale

1- The Licensee shall implement the tariff approved by EAC from time to time for the transmission service.

2- The Licensee shall implement the tariff approved by EAC from time to time for sale of electricity to Bulk Consumers or licensees.

## Condition 12: Settlement of Disputes relating to Transmission Agreement

1- Any dispute or difference between Licensee and a party to the Transmission Agreement relating to the Transmission Agreement shall be settled according to the provisions in that agreement.

## Condition 13: Health and Safety of Employees

1. The Licensee shall consult with persons employed by it in order to consider the matters of the health and safety of such persons.

| | |
|---|---|
| ១- រាល់ទំនាក់ទំនងទាំងអស់ពាក់ព័ន្ធជាមួយអាជ្ញាប័ណ្ណនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយយកភាសាខ្មែរជាគោល ។ | **Condition 14: Communication**<br>1. All communication relating to this License shall be written in Khmer as official. |
| **លក្ខខណ្ឌទី១៥: លក្ខខណ្ឌលក់មធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនីក្នុងករណីមានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា** | **Condition 15: Sale Conditions of the Transmission/ Sub-Transmission facility in case required by EAC** |
| ១- ក្នុងករណីដកហូតអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាចតម្រូវឱ្យអ្នកកាន់អាជ្ញាប័ណ្ណលក់ ឬផ្ទេរមធ្យោបាយធ្វើសេវាកម្មដែលបានចុះបញ្ជីនៅអាជ្ញាធរអគ្គិសនីកម្ពុជាឱ្យអ្នកបន្តវេនមួយផ្សេងទៀត ឬផ្ទេរទៅឱ្យអ្នកកាន់អាជ្ញាប័ណ្ណជាតិបញ្ជូនអគ្គិសនី ស្របតាមគោលការណ៍ហិរញ្ញវត្ថុ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ | 1. In case of revocation of the License, EAC can require the Licensee to sale its facilities to the successor or National Transmission Licensee in accordance with financial principles. |

# ឧបសម្ព័ន្ធទី១

## មធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយបញ្ជូនរងអគ្គិសនីកំណត់របស់អ្នកកាន់អាជ្ញាប័ណ្ណ

## SCHEDULE 1

## FIXED SPECIFIED TRANSMISSION/ SUB-TRANSMISSION FACILITIES OF THE LICENSEE

| | |
|---|---|
| - គ្រប់គ្រង និងដំណើរការខ្សែបណ្តាញ ២២ គីឡូវ៉ុល នៅតាមបណ្តោយផ្លូវជាតិលេខ ៦អា ចាប់ពីភូមិខ្នរ សង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ ទៅដល់តំបន់ថ្នល់កែង ឃុំសំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម, តាមបណ្តោយផ្លូវលេខ ៦១ ចាប់ពីថ្នល់កែង ទៅដល់តំបន់ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល និងចាប់ពីតំបន់ឃុំព្រែកតាមាក់ ទៅដល់តំបន់ឃុំព្រះប្រសប់ និងតំបន់ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងខ្សែបណ្តាញបំបែកពីខ្សែបណ្តាញមេ ។ | - Own and operate 22 kV line along the National Road No. 6A from Phum Khtor, Sangkat Prek Tasek, Khan Russey Keo to Thnal Keng area, Khum Sambo, Batheay District, Kampong Cham Province, along the road no. 61 from Thnal Keng to Khum Koh Chin, Ponnhea Leu District, Kandal Province and from Khum Prek Tamak to Khum Preah Brasob and Khum Puk Reussry, Khsach Kandal District, Kandal Province and the branch lines |

# ឧបសម្ព័ន្ធទី២

# ល័ក្ខខ័ណ្ឌសម្រាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ

**SCHEDULE 2**

**TERM OF LICENSE REVOCATION**

| | |
|---|---|
| ១- អាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការដកហូតអាជ្ញាប័ណ្ណណាមួយដែលបានផ្តល់ដោយឯកសារនេះបាន គ្រប់ពេលតាមកាលៈទេសៈដូចខាងក្រោម : | 1. EAC may at any time consider revocation of any of the licenses granted by this License Document under following circumstance: |
| (ក)- ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណសំណូមពរជាលាយលក្ខណ៍អក្សរ ទៅអាជ្ញាធរអគ្គិសនីកម្ពុជា សុំឱ្យដកហូតអាជ្ញាប័ណ្ណនេះ ឬ | (a) if the Licensee requests in writing to EAC that that such license may be revoked; or |
| (ខ)- ប្រសិនបើ ចំនួនទឹកប្រាក់ដែលត្រូវបង់ណាមួយតាមល័ក្ខខ័ណ្ឌទី៤នៃកាតព្វកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ ទាក់ទងជាមួយអាជ្ញាប័ណ្ណនេះមិនបានទូទាត់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយថ្ងៃដែលកំណត់ឱ្យបង់ ឬមិនបានទូទាត់ក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអាជ្ញាធរបានប្រគល់លិខិតជូនដំណឹងឱ្យទៅអ្នកកាន់អាជ្ញាប័ណ្ណថាថ្ងៃទូទាត់បានផុតកំណត់ហើយ ប៉ុន្តែលិខិតជូនដំណឹងនេះមិនត្រូវចេញមុន១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលចំនួនទឹកប្រាក់នេះត្រូវកំណត់ឱ្យបង់ឡើយ ។ | (b) if any amount payable under Condition 4 of General Obligation of Licensee in relation to such license is unpaid 30 days after it has become due or remains unpaid for a period of 14 days after EAC has given the Licensee notice that the payment is overdue provided that no such notice shall be given earlier than the fourteenth day after the day on which the amount payable became due; |
| (គ)- ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តិខុសពីល័ក្ខខ័ណ្ឌណាមួយនៃអាជ្ញាប័ណ្ណ និងមិនគោរពតាមបទបញ្ជាចុងក្រោយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការកែតម្រូវកំហុសនេះ ឬ | (c) if the Licensee in the opinion of the EAC has committed a material breach of any of the terms and Conditions of such License and does not comply with a final order of EAC to rectify such breach; or |
| (ឃ)- ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញភារកិច្ច និងកាតព្វកិច្ចដែលបានកំណត់ដោយអាជ្ញាប័ណ្ណនេះឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព,ឬ | (d) if the Licensee in the opinion of the EAC, is not in a position to fully and efficiently discharge the duties and obligations imposed on Licensee by such License; or |
| (ង)- ប្រសិនបើតាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តិខុសដោយចេតនា និងគ្មានហេតុផលចំពោះល័ក្ខខ័ណ្ឌដែលកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជារួមទាំងច្បាប់ការពារបរិស្ថាន សុវត្ថិភាព សុខភាព ពន្ធដារ ព្រមទាំងការអនុវត្តន៍ ការការពារ និងស្តង់ដានៃប្រព័ន្ធអគ្គិសនី ។ | (e) if in the opinion of EAC the Licensee has committed a willful or unreasonable default to comply with conditions set forth in the rules and regulations adopted by EAC, and the Laws of the Kingdom of Cambodia, including Laws regarding environmental protection, safety, health, taxes, and electric system performance, protection and standards; |
| ២- នៅគ្រប់ពេលអាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលមិនតិចជាង៣ខែទៅអ្នកកាន់អាជ្ញាប័ណ្ណស្តីពីមូលហេតុដែលឈរលើនេះអាជ្ញាប័ណ្ណណាមួយតម្រូវឱ្យដកហូត ។ | 2. EAC may at any time give not less than 3 months notice in writing to the Licensee stating the grounds on which any License is proposed to be revoked. |
| ៣- ជំនួសឱ្យការដកហូតអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុញ្ញាតឱ្យអាជ្ញាប័ណ្ណនេះបន្តនៅជាធរមានបន្តទៀត បើសិនជាមានល័ក្ខខ័ណ្ឌបន្ថែមទៀត ដែលយល់ថាគួរត្រូវដាក់ជំនួស រួចល័ក្ខខ័ណ្ឌបន្ថែមដែលត្រូវដាក់នេះ ត្រូវចងភ្ជាប់តាមផ្លូវច្បាប់ និងត្រូវប្រតិបត្តិតាមដោយអ្នកកាន់អាជ្ញាប័ណ្ណ និងត្រូវចូលជាធរមានដូចបានកំណត់ក្នុងអាជ្ញាប័ណ្ណ ដូច្នេះដែរ ។ | 3. EAC may, instead of revoking any License, permit it to remain in force subject to such further terms and conditions as considered fit to impose and any further terms or conditions imposed shall be binding upon and be observed by the Licensee, and be of like force and effect as if they were contained in the License. |

# ឧបសម្ព័ន្ធទី៣
# ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ

**SCHEDULE 3**
**OWNERSHIP OF LICENSEE**

| | |
|---|---|
| ១- អ្នកកាន់អាជ្ញាប័ណ្ណរួមមានម្ចាស់កម្មសិទ្ធិ ដែលបានចុះបញ្ជីក្នុង **ក្រុមហ៊ុន ធី ភី អិល ស៊ី ហូលឌីង** ដែលបានបែងចែកជា ១000 ភាគហ៊ុន ដូចខាងក្រោម : | 1. 1 The licensee has the following registered owners of the **TPLC Holdings Ltd.** with the 1000 shares are: |
| (ក) លោក **ភូ សេតុង** មានចំនួន ៩00 ភាគហ៊ុន ពីលេខ 000១ ដល់ 0៩00 | (a) Mr. Phu Sae Tong: 900 shares from 0001 to 0900 |
| (ខ) លោក **ភូ ណារិទ្ធ** មានចំនួន ១00 ភាគហ៊ុន ពីលេខ 0៩0១ ដល់ ១000 | (b) Mr. Phu Narith: 100 shares from 0901 to 1000 |
| ២- យោងតាមមាត្រា ៤៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់កម្មសិទ្ធិដែលបានចុះបញ្ជីដូចខាងលើ ពុំអាចមានភាគហ៊ុន ឬមានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ ជាមួយអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀតដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ ក្នុងករណីជាក់លាក់ណាមួយដើម្បីជាផលប្រយោជន៍សាធារណៈ អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីសម្រេចអនុញ្ញាតឱ្យបាន ។ | 2. Refer to Article 45 of the Electricity Law of the Kingdom of Cambodia, the above registered owners shall not own shares in or have any other direct financial interests in any other licensee without written permission from EAC. EAC may permit in specific cases in public interest. |